ក

មាតិកា

I_ខុទ្ទកាល័យព្រះមហាក្សត្រ

១_ព្រះរាជក្រម

១៣-៧-២០៤ -ព្រះរាជក្រម នស/រកម/០៧០៤/០០១ ស្តីពីការប្រកាសឱ្យប្រើ ច្បាប់ធម្មនុញ្ញបន្ថែម

២_ព្រះរាជក្រឹត្យ ១៤៣១

១៤-៧-២០៤ -ព្រះរាជក្រឹត្យ នស/រកត/០៧០៤/១១៧ ស្តីពីការចាត់តាំងសម្តេច **ហ៊ុន សែន ជានាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា** ១៤៣៥

១៥-៧-២០៤ -ព្រះរាជក្រឹត្យ នស/រកត/០៧០៤/១២៤ ស្តីពីការបញ្ចប់តំណែងរាជរដ្ឋាភិបាលចាស់ និង តែងតាំងរាជរដ្ឋាភិបាលថ្មី នៃព្រះរាជាណាចក្រកម្ពុជា ១៤៣៦

II_រាជរដ្ឋាភិបាល

១_អនុក្រឹត្យ

១២-៧-២០០៤ -អនុក្រឹត្យលេខ ៣៨៤ អនក្រ.តត ស្តីពីការតែងតាំងមុខតំណែងមន្ត្រីរាជការ ១៤៤៦

១២-៧-២០០៤ -អនុក្រឹត្យលេខ ៣៨៥ អនក្រ.តត ស្តីពីការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ ១៤៤៧

១២-៧-២០០៤ -អនុក្រឹត្យលេខ ៣៨៦ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៤៤៨

១២-៧-២០០៤ -អនុក្រឹត្យលេខ ៣៨៧ អនក្រ.តត ស្តីពីការបន្ថែមក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ ១៤៤៩

១៤-៧-២០០៤ -អនុក្រឹត្យលេខ ៣៨៨ អនក្រ.តត ស្តីពីការតែងតាំងមន្ត្រីរាជការ ១៤៥០

១៤-៧-២០០៤ -អនុក្រឹត្យលេខ ៣៨៩ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ១៤៥១

១៤-៧-២០០៤ -អនុក្រឹត្យលេខ ៣៩០ អនក្រ.តត ស្តីពីការជូនមេដាយសហមេត្រី ១៤៥២

១៤-៧-២០០៤ -អនុក្រឹត្យលេខ ៣៩១ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ១៤៥៣

១៤-៧-២០០៤ -អនុក្រឹត្យលេខ ៣៩២ អនក្រ.តត ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ ១៤៥៤

- អនុក្រឹត្យលេខ ៣៩៣ ពុំទាន់បានទទួល

២_សេចក្តីសំរេច

១៣-៧-២០០៤ -សេចក្តីសំរេចលេខ ៤១ សសរ ស្តីពីការបង្កើតគណៈកម្មការចំរុះ ចុះបង្ក្រាបបទល្មើសព្រៃឈើ នៅតំបន់កន្ទុយនាគ ក្នុងឧទ្យានជាតិវីរៈជ័យ ខេត្តរតនគីរី ១៤៥៥

III_ការិយាល័យក្រសួង

១_ទីស្តីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

០៩-៧-២០០៤ -ប្រកាសលេខ ១៣៣ MOC/M 2004 ស្តីពីការផ្ទេរអចលនវត្ថុ ១៤៥៨

១៥-៧-២០០៤ -ប្រកាសលេខ ១៤១ MOC/M2004 ស្តីពីការដាក់ឱ្យដេញថ្លៃលើកូតា សំលៀកបំពាក់ ដែលត្រូវនាំចេញទៅសហរដ្ឋអាមេរិក សំរាប់ប្រើប្រាស់ក្នុងឆ្នាំ ២០០៤ ១៤៦០

១៥-៧-២០០៤ - PRAKAS N° 141 MOC/M2004 On the Tender For Quota of Garments to be Exported to the United States of America ១៤៦៤

២_ទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

១២-៧-២០០៤ -ប្រកាសលេខ ២០៤ ប្រក.កសក ស្តីពីការកែប្រែនូវឧបសម្ព័ន្ធ ដែលភ្ជាប់ប្រកាសលេខ ០៦៤ ប្រក.កសក ចុះថ្ងៃទី ០៧ ខែ កុម្ភៈ ឆ្នាំ ២០០៣ ស្តីពីការដាក់ឱ្យប្រើប្រាស់គំរូពាក្យសុំ និងលិខិតអនុញ្ញាតឱ្យធ្វើអាជីវកម្ម សម្ភារៈកសិកម្ម ១៤៦៧

៣_ទីស្តីការរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា

១៣-៧-២០០៤ -ប្រកាសលេខ ២៦៥ សកបយ ស្តីពីការតែងតាំងក្រុមប្រឹក្សាអាជ្ញាកណ្តាល ១៥០៣

ព្រះរាជក្រម

នស/ រកម / ០៧០៤ / ០០១

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សម័យប្រជុំពេញអង្គលើកទី ១ នីតិកាលទី ៣ នៃរដ្ឋសភា នាថ្ងៃទី ៨ ខែ កក្កដា ឆ្នាំ ២០០៤
- បានទ្រង់យល់សម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ នៃព្រឹទ្ធសភា នាថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០៤
- យោងតាមសំណើ ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ២០០៤ របស់ព្រឹទ្ធសមាជិករដ្ឋសភា នីតិកាលទី៣

ប្រកាសឱ្យប្រើ

ច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ០៨ ខែ កក្កដា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គលើកទី ១ នីតិកាលទី ៣ ហើយដែលព្រឹទ្ធសភាបានឱ្យយោបល់យល់ព្រម កាលពីថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គលើកទី៩ នីតិកាលទី១ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅ :

ច្បាប់ធម្មនុញ្ញបន្ថែម
សំដៅ
ធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

មាត្រា ១.-

ច្បាប់ធម្មនុញ្ញនេះ មានគោលដៅធានាក្នុងគ្រប់កាលៈទេសៈនូវដំណើរការល្អប្រសើរនៃស្ថាប័នជាតិ ដោយគោរពទៅតាមគោលការណ៍ជាមូលដ្ឋាន នៃលទ្ធិប្រជាធិបតេយ្យសេរី-ពហុបក្ស សមស្របតាមតំរូវការនៃភាពចាំបាច់ ។

មាត្រា ២.-

នៅដើមនីតិកាលថ្មីនីមួយៗ រដ្ឋសភា ក្រោមអធិបតីភាពព្រឹទ្ធសមាជិករដ្ឋសភា មុននឹងផ្ដើមការងាររបស់ខ្លួន និង ក្រោយពេលសំរេចអំពីសុពលភាពនៃអាណត្តិរបស់សមាជិកម្នាក់ៗ អាចចាប់ផ្ដើមអនុម័ត អត្ថបទដែលមានចារិក ជារដ្ឋធម្មនុញ្ញ ឬ ច្បាប់ដើម្បីអនុវត្តបាននូវគោលដៅដូចមានចែងក្នុងមាត្រា ១ ។

អត្ថបទទាំងនេះ ក្រោយពីបានត្រូវទទួលការបោះឆ្នោតអនុម័តដោយរដ្ឋសភារួចហើយ ត្រូវតែបានទទួលជាបន្ទាន់នូវចំណាត់ការដោយរួសរាន់ពីសំណាក់ព្រឹទ្ធសមាជិករដ្ឋសភា តាមនីតិវិធីកំណត់សំរាប់ អត្ថបទទាំងនោះ រហូតដល់ពេលដែលត្រូវបានប្រកាសអោយចូលជាធរមាន ។

មាត្រា ៣.-

ក្នុងករណីដែលឃើញថានីតិវិធីនៃមាត្រា ៨២ និង ១១៩ថ្មី នៃរដ្ឋធម្មនុញ្ញ មិនអាចសំរេចបាន រដ្ឋសភា តាមសំណើររបស់គណបក្សដែលមានអាសនៈច្រើនជាងគេនៅក្នុងរដ្ឋសភា អាចដំណើរការការបោះឆ្នោតជាកញ្ចប់ ដើម្បី ជ្រើសតាំងប្រធាន អនុប្រធានរដ្ឋសភា ក៏ដូចជា ប្រធាន និង អនុប្រធានគណៈ កម្មការក្នុងពេលជាមួយគ្នា និង ការផ្ដល់សេចក្ដីទុកចិត្តចំពោះ រាជរដ្ឋាភិបាល ។

មាត្រា ៤.-

ការរៀបចំបញ្ជីរាយនាមបេក្ខជន ដើម្បីបោះឆ្នោតជ្រើសតាំង និង ផ្ដល់សេចក្ដីទុកចិត្ត ត្រូវអនុវត្តដូចតទៅ :

- បញ្ជីរាយនាមបេក្ខជនប្រធាន អនុប្រធាននៃរដ្ឋសភា ក៏ដូចជា ប្រធាន និង អនុប្រធានគណៈ កម្មការ ជំនាញទាំងអស់ នៃរដ្ឋសភា ត្រូវរៀបចំ និង ស្នើដោយគណបក្សនយោបាយដែលព្រមព្រៀងគ្នា ដើម្បីបង្កើតរាជរដ្ឋាភិបាលចំរុះ ហើយត្រូវផ្ញើជូនព្រឹទ្ធសមាជិករដ្ឋសភា ។

- តាមសេចក្ដីស្នើពីគណបក្សនយោបាយ ដែលមានចំនួនអាសនៈច្រើនជាងគេនៅក្នុងរដ្ឋសភា តាមរយៈព្រឹទ្ធសមាជិករដ្ឋសភា ព្រះមហាក្សត្រទ្រង់ចាត់តាំងវរជនមួយរូបក្នុងចំណោមតំណាងរាស្ត្រ នៃគណបក្សនយោបាយដែលឈ្នះឆ្នោតអោយបង្កើតរាជរដ្ឋាភិបាល ។

វរជនដែលត្រូវបានចាត់តាំងនេះ ត្រូវរៀបចំផ្គូរផ្គងតំណែងផ្សេងៗក្នុងរាជរដ្ឋាភិបាល រួចផ្ញើបញ្ជី រាយនាម សមាជិកទាំងអស់នៃរាជរដ្ឋាភិបាលជូនព្រឹទ្ធសមាជិករដ្ឋសភា ។

- ព្រឹទ្ធសមាជិករដ្ឋសភា ត្រូវរៀបចំបញ្ជីរាយនាមជាកញ្ចប់មួយនូវបេក្ខជន ប្រធាន អនុប្រធាន នៃរដ្ឋសភា ក៏ដូចជាប្រធាន និង អនុប្រធានគណកម្មការ ជំនាញទាំងអស់នៃរដ្ឋសភា ព្រមទាំងបេក្ខជន នាយករដ្ឋមន្ត្រី និង សមាជិកទាំងអស់នៃរាជរដ្ឋាភិបាល ដើម្បីដាក់ជូនរដ្ឋសភាបោះឆ្នោត ។

មាត្រា ៥.-

នៅក្នុងដំណើរការនៃការបោះឆ្នោតជាកញ្ចប់ មិនអាចជជែកពិភាក្សាអ្វីឡើយ ហើយក៏មិនអាចមានការពន្យល់អំពីការបោះឆ្នោតនេះ ក្រោយការប្រកាសលទ្ធផល នៃការបោះឆ្នោតជាកញ្ចប់នេះដែរ ។

សមាជិករដ្ឋសភា ត្រូវធ្វើការបោះឆ្នោតដោយបញ្ជាក់ថាព្រម ឬ មិនព្រមចំពោះបញ្ជីរាយនាមជាកញ្ចប់មួយ ដែលព្រឹទ្ធសមាជិករដ្ឋសភាបានដាក់ជូន ។ ការបោះឆ្នោតនេះត្រូវធ្វើឡើងដោយវិធីលើកដៃ ។

មាត្រា ៦.-

ការបោះឆ្នោតជាកញ្ចប់ខាងលើនេះ ត្រូវយកតាមមតិភាគច្រើន ពីរភាគបី នៃសមាជិករដ្ឋសភាទាំងមូល ។

ក្នុងករណី ការបោះឆ្នោតជុំទីមួយមិនបានសំរេច នីតិវិធីដដែលនេះ នឹងត្រូវអនុវត្តចំពោះការបោះឆ្នោតជុំក្រោយៗទៀត ។

មាត្រា ៧.-

ច្បាប់ធម្មនុញ្ញបន្ថែមនេះ ត្រូវបានប្រកាសជាការប្រញាប់ និង យកមកអនុវត្តចាប់តាំងពីដើម នីតិកាល បច្ចុប្បន្ននេះទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០៤

ជួសព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

៣រល.០៤.០៧.១១៧

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ជករ

ញឹក ប៊ុនឆៃ

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

ព្រឹទ្ធសមាជិក និង ជាប្រធានអគ្គប្រជុំរដ្ឋសភា

ហត្ថលេខា

ជា ស៊ីម

លេខ: ៩៤០ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ.ថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

សាវី តាន់

នស/រកត/០៧០៤/១១៧

ព្រះរាជក្រឹត្យ

យើង

ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ
រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍
និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ
ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- យោងលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នាថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ២០០៣
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- យោងតាមសំណើរបស់គណបក្សប្រជាជនកម្ពុជា ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ២០០៤
- យោងតាមសំណើរបស់ក្រុមសមាជិករដ្ឋសភា ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ២០០៤

ត្រាស់បង្គាប់

មាត្រា ១.-

តែងតាំងសម្ដេច ហ៊ុន សែន ជានាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា។

មាត្រា ២.-

នាយករដ្ឋមន្ត្រី មានភារកិច្ចរៀបចំសមាសភាពរាជរដ្ឋាភិបាលកម្ពុជា ដើម្បីសុំសេចក្ដីអនុម័តទុកចិត្តពីរដ្ឋសភា។

មាត្រា ៣.-

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា

នរោត្តម សីហនុ

ការ.០៤.០៧.១១៨
បានប្រថាប់ព្រះរាជលញ្ឆករហើយ
ធ្វើនៅថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ២០០៤

លេខ: ០០៥/០៤ រ.ចច
បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ២០០៤
ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីព្រះបរមរាជវាំង
ហត្ថលេខា
គង់ សំអុល

លេខ: ៩១ . ចល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ២០០៤
អគ្គលេខាធិការរាជរដ្ឋាភិបាល
[illegible] តាន់

ព្រះរាជក្រឹត្យ

នស/រកត/០៧០៤/១២៤

យើង

ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ

រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតន៍

និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ

ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមលទ្ធផលនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នាថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៣
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១១៧ ចុះថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការចាត់តាំងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៧/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមលទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី៣នៃរដ្ឋសភានាថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធ និងថ្នាក់ដឹកនាំនៃរដ្ឋសភា និងសំដែងការទុកចិត្តទៅលើសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- យោងតាមសំណើរបស់នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤

ត្រាស់បង្គាប់

មាត្រា១.-

ត្រូវបានបញ្ចប់តំណែងរាជរដ្ឋាភិបាលកម្ពុជា ដែលបានតែងតាំងដោយព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ហើយដែលកែសំរួលដោយ ព្រះរាជក្រឹត្យ លេខ នស/រកត/០៤៩៩/៩១ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ១៩៩៩ ដោយព្រះរាជក្រឹត្យលេខ នស/រកត/០៨០០/១៤៥ ចុះថ្ងៃទី ០៥ ខែ សីហា ឆ្នាំ ២០០០ និងដោយព្រះរាជក្រឹត្យលេខ

នស/រកត/០៨០១/២៨៧ ចុះថ្ងៃទី២៤ ខែសីហា ឆ្នាំ២០០១ និង តែងតាំងរាជរដ្ឋាភិបាល នៃ ព្រះរាជាណាចក្រកម្ពុជា ដែលមានសមាសភាពក្រសួង និង រដ្ឋលេខាធិការដ្ឋាន ដូចតទៅៈ

I- នាយករដ្ឋមន្ត្រី :

សម្តេច ហ៊ុន សែន

II- ឧបនាយករដ្ឋមន្ត្រី

១- ឯកឧត្តម ស ខេង
២- ស្តេចក្រុមឃុន នរោត្តម សិរីវុឌ្ឍ
៣- ឯកឧត្តម សុខ អាន
៤- ឯកឧត្តម លី ឡាយស្រេង
៥- ឯកឧត្តម ទៀ បាញ់
៦- ឯកឧត្តម ហោ ណាំហុង
៧- ឯកឧត្តម ញឹក ប៊ុនឆៃ

III- ទេសរដ្ឋមន្ត្រី

១- ឯកឧត្តម គាត ឈន់
២- ឯកឧត្តម យូ ហុកគ្រី (ទទួលបន្ទុកបេសកកម្មពិសេស)
៣- ឯកឧត្តម អ៊ឹម ឈុនលឹម
៤- ឯកឧត្តម ហុង ស៊ុនហួត (ទទួលបន្ទុកបេសកកម្មពិសេស)
៥- លោកជំទាវ ម៉ែន សំអន
៦- ឯកឧត្តម ឃី តាំងលឹម (ទទួលបន្ទុកបេសកកម្មពិសេស)
៧- ឯកឧត្តម ឆាយ ថន
៨- ឯកឧត្តម វ៉េង សិរីវុឌ្ឍ (ទទួលបន្ទុកបេសកកម្មពិសេស)
៩- ឯកឧត្តម ចម ប្រសិទ្ធ
១០- ឯកឧត្តម ម៉ុក ម៉ារ៉េត
១១- ឯកឧត្តម ឃុន ហាំង
១២- ឯកឧត្តម ញឹម វណ្ណដា (ទទួលបន្ទុកបេសកកម្មពិសេស)
១៣- ឯកឧត្តម កុល ផេង
១៤- ឯកឧត្តម តាវ សេងហួរ (ទទួលបន្ទុកបេសកកម្មពិសេស)

១៥-	ឯកឧត្តម	សេរី	កុសល	(ទទួលបន្ទុកបេសកកម្មពិសេស)

ក្រសួង និងស្ថាប័ន

១- ទីស្តីការគណៈរដ្ឋមន្ត្រី

១-	ឯកឧត្តម	សុខ	អាន	រដ្ឋមន្ត្រី
២-	ឯកឧត្តម	ប្រាក់	សុខុន	រដ្ឋលេខាធិការ
៣-	ឯកឧត្តម	ជា	សោភ័ណ	រដ្ឋលេខាធិការ
៤-	ឯកឧត្តម	ប៊ិន	អ៊ុយ	រដ្ឋលេខាធិការ
៥-	ឯកឧត្តម	ខូវ	ម៉េងហ៊ាន	រដ្ឋលេខាធិការ
៦-	ឯកឧត្តម	សេង	លឹមនៅ	រដ្ឋលេខាធិការ
៧-	ឯកឧត្តម	កាន់	ម៉ន	រដ្ឋលេខាធិការ
៨-	ឯកឧត្តម	ង៉ោ	ស្រ៊ិន	រដ្ឋលេខាធិការ

២- ក្រសួងមហាផ្ទៃ

១-	ឯកឧត្តម	ស	ខេង	សហរដ្ឋមន្ត្រី
២-	ស្តេចក្រុមឃុន	នរោត្តម	សិរីវុឌ្ឍ	សហរដ្ឋមន្ត្រី
៣-	ឯកឧត្តម	ឯម	សំអាន	រដ្ឋលេខាធិការ
៤-	ឯកឧត្តម	ខាន់	សាវឿន	រដ្ឋលេខាធិការ
៥-	ឯកឧត្តម	ព្រុំ	សុខា	រដ្ឋលេខាធិការ
៦-	ឯកឧត្តម	គង់	ហ៊ុនធារិទ្ធ	រដ្ឋលេខាធិការ
៧-	ឯកឧត្តម	នុត	សាអាន	រដ្ឋលេខាធិការ

៣- ក្រសួងការពារជាតិ

១-	ឯកឧត្តម	ទៀ	បាញ់	សហរដ្ឋមន្ត្រី
២-	ឯកឧត្តម	ញឹក	ប៊ុនឆៃ	សហរដ្ឋមន្ត្រី
៣-	ឯកឧត្តម	ចាយ	សាំងយុន	រដ្ឋលេខាធិការ
៤-	ឯកឧត្តម	ហាក់	សាវុធ	រដ្ឋលេខាធិការ
៥-	ឯកឧត្តម	ម៉ឹង	សំផន	រដ្ឋលេខាធិការ
៦-	ឯកឧត្តម	ស៊ឹង្ហ	គីរី	រដ្ឋលេខាធិការ
៧-	ឯកឧត្តម	នាង	ផាត	រដ្ឋលេខាធិការ

៤- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

១-	ឯកឧត្តម	ហោ	ណាំហុង	រដ្ឋមន្ត្រី
២-	ឯកឧត្តម	ឡុង	វិសាលោ	រដ្ឋលេខាធិការ
៣-	ឯកឧត្តម	ហ៊ុយ	កន្ធលវ៉ា	រដ្ឋលេខាធិការ
៤-	ឯកឧត្តម	អ៊ុច	បូរិទ្ធ	រដ្ឋលេខាធិការ
៥-	ព្រះអង្គម្ចាស់	ស៊ីសុវត្ថិ	ធីរ៉ៃណារិទ្ធ	រដ្ឋលេខាធិការ
៦-	ឯកឧត្តម	កៅ	គឹមហួន	រដ្ឋលេខាធិការ

៥- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

១-	ឯកឧត្តម	គាត	ឈន់	រដ្ឋមន្ត្រី
២-	ឯកឧត្តម	គង់	វិបុល	រដ្ឋលេខាធិការទី ១ មានឋានៈស្មើ រដ្ឋមន្ត្រី
៣-	ឯកឧត្តម	អ៊ុក	រ៉ាប៊ុន	រដ្ឋលេខាធិការ
៤-	ឯកឧត្តម	ជា	ប៉េងឈាង	រដ្ឋលេខាធិការ
៥-	ឯកឧត្តម	អូន	ព័ន្ធមុនីរ័ត្ន	រដ្ឋលេខាធិការ
៦-	ឯកឧត្តម	អ៊ូ	ប៊ុនឡុង	រដ្ឋលេខាធិការ
៧-	ឯកឧត្តម	ប៊ុន	សម	រដ្ឋលេខាធិការ

៦- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

១-	ឯកឧត្តម	ច័ន្ទ	សារុន	រដ្ឋមន្ត្រី
២-	ឯកឧត្តម	ច័ន្ទ	តុងអ៊ីវ	រដ្ឋលេខាធិការ
៣-	ឯកឧត្តម	យឹម	វឿនថន	រដ្ឋលេខាធិការ
៤-	ឯកឧត្តម	ប៉ោ	ទ្រី	រដ្ឋលេខាធិការ
៥-	ឯកឧត្តម	លឹម	សូគុន	រដ្ឋលេខាធិការ
៦-	ឯកឧត្តម	តេង	ឡៅ	រដ្ឋលេខាធិការ

៧- ក្រសួងអភិវឌ្ឍន៍ជនបទ

១-	ឯកឧត្តម	លី	ឡាយស្រេង	រដ្ឋមន្ត្រី
២-	ឯកឧត្តម	អ៊ិន	ចន្ទា	រដ្ឋលេខាធិការ
៣-	ឯកឧត្តម	យឹម	ឆៃលី	រដ្ឋលេខាធិការ
៤-	ឯកឧត្តម	ជន	សាមួន	រដ្ឋលេខាធិការ

៥-	ឯកឧត្តម	សួស	គង់	រដ្ឋលេខាធិការ
៦-	ឯកឧត្តម	លី	ប្រុស	រដ្ឋលេខាធិការ

៨- ក្រសួងពាណិជ្ជកម្ម

១-	ឯកឧត្តម	ចម	ប្រសិទ្ធ	រដ្ឋមន្ត្រី
២-	ឯកឧត្តម	សុក	ស៊ីផាន់ណា	រដ្ឋលេខាធិការ
៣-	ឯកឧត្តម	ង៉ែ	ឆាយលាង	រដ្ឋលេខាធិការ
៤-	ឯកឧត្តម	គឹម	ស៊ីថន	រដ្ឋលេខាធិការ
៥-	ឯកឧត្តម	គួច	គី	រដ្ឋលេខាធិការ
៦-	ឯកឧត្តម	ឱក	ប៊ុង	រដ្ឋលេខាធិការ

៩- ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

១-	ឯកឧត្តម	ស៊ុយ	សែម	រដ្ឋមន្ត្រី
២-	ឯកឧត្តម	អ៊ិត	ប្រាំង	រដ្ឋលេខាធិការ
៣-	ឯកឧត្តម	ភោគ	សុវណ្ណរិទ្ធ	រដ្ឋលេខាធិការ
៤-	ឯកឧត្តម	ខ្លូត	វ៉ាន់ឌី	រដ្ឋលេខាធិការ
៥-	ឯកឧត្តម	ជា	សាងហុង	រដ្ឋលេខាធិការ
៦-	ឯកឧត្តម	ញ៉ឹក	ច្រឹង	រដ្ឋលេខាធិការ

១០- ក្រសួងផែនការ

១-	ឯកឧត្តម	ឆាយ	ថន	រដ្ឋមន្ត្រី
២-	ឯកឧត្តម	អ៊ូ	ឱហាត	រដ្ឋលេខាធិការ
៣-	ឯកឧត្តម	ឆឹង	ចំរើន	រដ្ឋលេខាធិការ
៤-	ឯកឧត្តម	ហ៊ុល	លឹម	រដ្ឋលេខាធិការ
៥-	ឯកឧត្តម	គួ	ហ្គារី	រដ្ឋលេខាធិការ
៦-	ឯកឧត្តម	អ៊ុក	ចាយ	រដ្ឋលេខាធិការ

១១- ក្រសួងអប់រំ យុវជន និងកីឡា

១-	ឯកឧត្តម	កុល	ផេង	រដ្ឋមន្ត្រី
២-	ឯកឧត្តម	ប៉ុក	ថន	រដ្ឋលេខាធិការ
៣-	ឯកឧត្តម	អ៊ុម	សិទ្ធី	រដ្ឋលេខាធិការ

៤-	ឯកឧត្តម	ម៉ក់	វ៉ាន់	រដ្ឋលេខាធិការ
៥-	ឯកឧត្តម	ពិត	ចំណាន	រដ្ឋលេខាធិការ
៦-	ឯកឧត្តម	ប៊ុន	សុខ	រដ្ឋលេខាធិការ

១២- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

១-	ឯកឧត្តម	អ៊ិត	សំហេង	រដ្ឋមន្ត្រី
២-	ឯកឧត្តម	នឹម	ថូត	រដ្ឋលេខាធិការ
៣-	ឯកឧត្តម	អ៊ឹង	ទាស៊ាម	រដ្ឋលេខាធិការ
៤-	ឯកឧត្តម	យី	យ៉ូន	រដ្ឋលេខាធិការ
៥-	ឯកឧត្តម	យឹម	រាជលិញ	រដ្ឋលេខាធិការ
៦-	ឯកឧត្តម	សយ	ស៊ីផុន	រដ្ឋលេខាធិការ

១៣- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

១-	ឯកឧត្តម	អ៊ឹម	ឈុនលឹម	រដ្ឋមន្ត្រី
២-	ឯកឧត្តម	ជា	សុផារ៉ា	រដ្ឋលេខាធិការ
៣-	ឯកឧត្តម	ភឿង	សុភ័ណ	រដ្ឋលេខាធិការ
៤-	ឯកឧត្តម	នុត	ណារ៉ាង	រដ្ឋលេខាធិការ
៥-	ឯកឧត្តម	កែវ	ខេមរ៉ា	រដ្ឋលេខាធិការ
៦-	ឯកឧត្តម	ឆាន់	សាផាន	រដ្ឋលេខាធិការ

១៤- ក្រសួងបរិស្ថាន

១-	ឯកឧត្តម	ម៉ុក	ម៉ារ៉េត	រដ្ឋមន្ត្រី
២-	ឯកឧត្តម	ប្រាជ្ញ	ស៊ុន	រដ្ឋលេខាធិការ
៣-	ឯកឧត្តម	តាន់	វុត្ថា	រដ្ឋលេខាធិការ
៤-	ឯកឧត្តម	ខៀវ	មុត	រដ្ឋលេខាធិការ
៥-	ឯកឧត្តម	ខុង	សំនួន	រដ្ឋលេខាធិការ
៦-	ឯកឧត្តម	យិន	គឹមស៊ាន	រដ្ឋលេខាធិការ

១៥- ក្រសួងធនធានទឹក និងឧតុនិយម

១-	ឯកឧត្តម	លឹម	គានហោ	រដ្ឋមន្ត្រី
២-	ឯកឧត្តម	អ៊ី	គីហ៊ាង	រដ្ឋលេខាធិការ

៣- ឯកឧត្តម ង៉ោ ពិន រដ្ឋលេខាធិការ
៤- ឯកឧត្តម សំ សារិត រដ្ឋលេខាធិការ
៥- លោកជំទាវ ជា រដ្ឋា រដ្ឋលេខាធិការ
៦- ឯកឧត្តម វ៉េង សាខុន រដ្ឋលេខាធិការ

១៦- ក្រសួងពត៌មាន

១- ឯកឧត្តម ខៀវ កាញារីទ្ធ រដ្ឋមន្ត្រី
២- ឯកឧត្តម អ៊ិក ប្រាថ្នា រដ្ឋលេខាធិការ
៣- ឯកឧត្តម គាន់ ស៊ីថាន់ រដ្ឋលេខាធិការ
៤- ឯកឧត្តម ម៉ៅ អាយុទ្ធ រដ្ឋលេខាធិការ
៥- ឯកឧត្តម ហោ សុភាព រដ្ឋលេខាធិការ
៦- ឯកឧត្តម ថាច់ ផែន រដ្ឋលេខាធិការ

១៧- ក្រសួងយុត្តិធម៌

១- ឯកឧត្តម អង្គ វង្សវឌ្ឍានា រដ្ឋមន្ត្រី
២- ឯកឧត្តម អ៊ុំ ផន រដ្ឋលេខាធិការ
៣- ឯកឧត្តម នៅ កាស៊ី រដ្ឋលេខាធិការ
៤- ឯកឧត្តម ហ៊ី សោភា រដ្ឋលេខាធិការ
៥- ឯកឧត្តម ទូច ណុច រដ្ឋលេខាធិការ
៦- ឯកឧត្តម ឡុង ផុល រដ្ឋលេខាធិការ

១៨- ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច

១- លោកជំទាវ ម៉ែន សំអន រដ្ឋមន្ត្រី
២- ឯកឧត្តម ហុង ថៃម រដ្ឋលេខាធិការ
៣- ឯកឧត្តម ស៊ុយ នូ រដ្ឋលេខាធិការ
៤- ឯកឧត្តម ប្រាក់ ហម រដ្ឋលេខាធិការ
៥- ឯកឧត្តម ម៉ៅ សម្បត្តិ រដ្ឋលេខាធិការ
៦- ឯកឧត្តម ឡេង ប៉េងឡុង រដ្ឋលេខាធិការ

១៩- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍

១- ឯកឧត្តម សូរ យុន រដ្ឋមន្ត្រី

២-	ឯកឧត្តម	ជិន	ប៊ុនស៊ាន	រដ្ឋលេខាធិការ
៣-	ឯកឧត្តម	ឯក	វណ្ណឌី	រដ្ឋលេខាធិការ
៤-	ឯកឧត្តម	ឡា	ណារ៉ាត	រដ្ឋលេខាធិការ
៥-	ឯកឧត្តម	ខាយ	ឃុនហេង	រដ្ឋលេខាធិការ
៦-	ឯកឧត្តម	សារ៉ាក់	ខាន់	រដ្ឋលេខាធិការ

២០- ក្រសួងសុខាភិបាល

១-	ឯកឧត្តម	នុត	សុខុម	រដ្ឋមន្ត្រី
២-	ឯកឧត្តម	អ៊ឹង	ភីរុន	រដ្ឋលេខាធិការ
៣-	ឯកឧត្តម	ម៉ម	ប៊ុនហេង	រដ្ឋលេខាធិការ
៤-	លោកជំទាវ	អ៊ុក	ប៊ុណ្ណា	រដ្ឋលេខាធិការ
៥-	ឯកឧត្តម	ហេង	តៃគ្រី	រដ្ឋលេខាធិការ
៦-	ឯកឧត្តម	អេង	ហួត	រដ្ឋលេខាធិការ

២១- ក្រសួងសាធារណការ និងដឹកជញ្ជូន

១-	ឯកឧត្តម	ស៊ុន	ចាន់ថុល	រដ្ឋមន្ត្រី
២-	ឯកឧត្តម	សួង	ហេង	រដ្ឋលេខាធិការ
៣-	ឯកឧត្តម	ត្រាំ	អ៊ីវតឹក	រដ្ឋលេខាធិការ
៤-	ឯកឧត្តម	ជុំ	អៀក	រដ្ឋលេខាធិការ
៥-	ឯកឧត្តម	អ៊ុក	ចាន់	រដ្ឋលេខាធិការ
៦-	ឯកឧត្តម	ម៉ុម	ស៊ីបុន	រដ្ឋលេខាធិការ

២២- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

១-	អ្នកអង្គម្ចាស់	ស៊ីសុវត្ថិ	ប៉ាណារ៉ា ស៊ីរីវុឌ្ឍ	រដ្ឋមន្ត្រី
២-	អ្នកអង្គម្ចាស់	ស៊ីសុវត្ថិ	កូឡាឆាត	រដ្ឋលេខាធិការ
៣-	ឯកឧត្តម	ហ៊ឹម	ឆែម	រដ្ឋលេខាធិការ
៤-	ឯកឧត្តម	អ៊ិន	ស៊ីយ៉ុន្ថា	រដ្ឋលេខាធិការ
៥-	ឯកឧត្តម	ជុច	ភឿន	រដ្ឋលេខាធិការ
៦-	ឯកឧត្តម	ឃឹម	សារិទ្ធ	រដ្ឋលេខាធិការ

២៣- ក្រសួងទេសចរណ៍

១- ឯកឧត្តម ឡាយ ព្រហស្ស រដ្ឋមន្ត្រី
២- ព្រះអង្គម្ចាស់ក្សត្រី នរោត្តម រតនាទេវី រដ្ឋលេខាធិការ
៣- ឯកឧត្តម ថោង ខុន រដ្ឋលេខាធិការ
៤- ឯកឧត្តម នុត និនជឿន រដ្ឋលេខាធិការ
៥- ឯកឧត្តម សម ព្រហ្មនា រដ្ឋលេខាធិការ
៦- ឯកឧត្តម រស់ រ៉េន រដ្ឋលេខាធិការ

២៤- ក្រសួងធម្មការ និងកិច្ចការសាសនា

១- ឯកឧត្តម ឃុន ហាំង រដ្ឋមន្ត្រី
២- ឯកឧត្តម ស៊ុន គីមហ៊ុន រដ្ឋលេខាធិការ
៣- ឯកឧត្តម ឈន អៀម រដ្ឋលេខាធិការ
៤- ឯកឧត្តម ស៊ិត អ៊ីប្រាហ៊ីម រដ្ឋលេខាធិការ
៥- ឯកឧត្តម មិន ឃិន រដ្ឋលេខាធិការ
៦- ឯកឧត្តម ហ្សាការីយ៉ា អាដាម រដ្ឋលេខាធិការ

២៥- ក្រសួងកិច្ចការនារី

១- លោកជំទាវ អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រី
២- លោកជំទាវ ឃឹម ចំរើន រដ្ឋលេខាធិការ
៣- លោកជំទាវ សោម គឹមសួគ៌ រដ្ឋលេខាធិការ
៤- លោកជំទាវ អ៊ឹម ស៊ីថៃ រដ្ឋលេខាធិការ
៥- លោកជំទាវ យូ អយ រដ្ឋលេខាធិការ
៦- លោកជំទាវ ច័ន្ទ សូរិយ៍ រដ្ឋលេខាធិការ

២៦- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- ឯកឧត្តម ញ៉ែប ប៊ុនជិន រដ្ឋមន្ត្រី
២- ឯកឧត្តម សុខ សាន រដ្ឋលេខាធិការ
៣- ឯកឧត្តម វង សួត រដ្ឋលេខាធិការ
៤- លោកជំទាវ ប្រាក់ ចន្ថា រដ្ឋលេខាធិការ
៥- ឯកឧត្តម អូស្មាន ហាស្សាន់ រដ្ឋលេខាធិការ

៦- ឯកឧត្តម ពេជ្រ សោភ័ណ រដ្ឋលេខាធិការ

រដ្ឋលេខាធិការដ្ឋានចំណុះទីស្តីការគណៈរដ្ឋមន្ត្រី

១- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

- ឯកឧត្តម ពេជ្រ ប៊ុនធិន រដ្ឋលេខាធិការ

២- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល

- ឯកឧត្តម ម៉ៅ ហាសវណ្ណាល់ រដ្ឋលេខាធិការ

មាត្រា២.-

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចតាមព្រះរាជក្រឹត្យនេះ ។

មាត្រា៣.-

ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា

នរោត្តម សីហនុ

៣៖ស.០៤-០៧.១២៥

លេខ: ៩២៤ ច.ល

ធ្វើនៅថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ ២០០៤

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ,ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាងឌី តាន់

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៧៧៤ អនក្រ.តត

អនុក្រឹត្យ

ស្តីពី

ការតែងតាំងមុខតំណែងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១ ៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ .

ស ំ រេ ច

មាត្រា ១ : ត្រូវបានតែងតាំងលោក **ឈឹម សាខន** ឋានន្តរសក្តិ វរសេនីយ៍ឯក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ ឱ្យមកទទួលមុខតំណែងជាអភិបាលរងទី១ ខេត្តស្វាយរៀង ។

មាត្រា ២ : លោកវរសេនីយ៍ឯក **ឈឹម សាខន** ត្រូវបានទទួលប្រាក់បំណាច់មុខងារក្នុងមុខតំណែងថ្មីនេះ ស្របតាមព្រះរាជក្រឹត្យលេខនស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែ ធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាន និងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល ។ ក្នុងរយៈពេលបំពេញភារកិច្ចថ្មីនេះ សាមីខ្លួនត្រូវដាក់ពាក្យសុំស្ថិតនៅក្រៅក្របខ័ណ្ឌដើម ។

មាត្រា ៣ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័ន ដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ៦ ខែ កក្កដា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចម្លងជូន :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)
- ដូចមាត្រា ៤ (ដើម្បីអនុវត្ត)
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៧៩៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការតម្លើងឋានន្តរសក្តិនាយនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /០៥០១ /១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានតម្លើងឋានន្តរសក្តិថ្នាក់ **វរៈសេនីយ៍ឯក** ជូននាយនគរបាលជាតិជាន់ខ្ពស់ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ដូចមានរាយនាមខាងក្រោម :

១-លោកវរៈសេនីយ៍ទោ រស់ សារ៉ាត់ អត្តលេខ ០៦១០ ។

២-លោកវរៈសេនីយ៍ទោ សៅ ស្រស់ អត្តលេខ ០៧៨៧ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ. ថ្ងៃទី ១២ -ខែ កក្កដា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៣៤៦ អនក្រ.តត

អនុក្រឹត្យ
ស្តីពី
ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤/ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០៦៩៩/០៨ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងធនធានទឹក និងឧតុនិយម
- បានឃើញអនុក្រឹត្យ លេខ ៥៨ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មិថុនា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងធនធានទឹក និងឧតុនិយម
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម

សម្រេច

មាត្រា ១.-

ត្រូវបានតែងតាំង លោក **ម៉ៅ ហាក់** ជាប្រធាននាយកដ្ឋានជលសាស្ត្រ និងការងារទន្លេ នៃក្រសួងធនធានទឹក និងឧតុនិយម ។

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃ ចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤

ហ៊ុន សែន

កន្លែងទទួល :
- *-ក្រសួងព្រះបរមរាជវាំង*
- *-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *-អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *-អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *-ដូចមាត្រា ១ និង មាត្រា ២*
- *-ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៣៤៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការបន្ថែមក្របខ័ណ្ឌមន្ត្រីនគរបាលជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម /០១/៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /០៥០១ /១៧៨ ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីនគរបាលជាតិកម្ពុជា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានបន្ថែមក្របខ័ណ្ឌមន្ត្រីនគរបាលជាតិចំនួន ៧០០ កន្លែង (ប្រាំពីររយ) ដល់ក្រសួងមហាផ្ទៃ សំរាប់បំពេញតម្រូវការចាំបាច់នៃការងារការពារសន្តិសុខជាតិ ថែរក្សាសណ្តាប់ធ្នាប់សាធារណៈ និងសុវត្ថិភាពសង្គម ។

មាត្រា ២ : ក្របខ័ណ្ឌបន្ថែមថ្មីនេះ ត្រូវបានទទួលប្រាក់បៀវត្សរ៍ និងរបបឧបត្ថម្ភផ្សេងៗ របស់មន្ត្រីនគរបាលជាតិ ចាប់ពីខែ មករា ឆ្នាំ ២០០៥ តទៅ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ៣៨៨.អនក្រ.តត

អនុក្រឹត្យ

ស្តីពីការតែងតាំងមន្ត្រីរាជការ

****

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រឹត្យលេខ NS/KRT-34 ចុះថ្ងៃទី ២៧ ខែឧសភា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតក្រសួងព្រះបរមរាជវាំង ។
- យោងលិខិតលេខ ១៥៥ មស.តត ចុះថ្ងៃទី ៩ ខែ កក្កដា ឆ្នាំ ២០០៤ របស់រដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ ។
- យោងលិខិតលេខ ១៦៣/០៤ វវ.លស ចុះថ្ងៃទី ១២ ខែ កក្កដា ឆ្នាំ ២០០៤ របស់ក្រសួងព្រះបរមរាជវាំង ។

ស ំ រេ ច

មាត្រា ១ : តែងតាំងមន្ត្រីរាជការក្រសួងព្រះបរមរាជវាំង ចំនួន ០៥ រូប ដូចមានរាយនាមខាងក្រោម :

១- លោក ទួន វណ្ណៈ អនុប្រធាននាយកដ្ឋានទំនាក់ទំនង ជាជំនួយការឯកឧត្តម ឧបនាយករដ្ឋមន្ត្រី និងជា រដ្ឋមន្ត្រីព្រះបរមរាជវាំង មានឋានៈស្មើប្រធាននាយកដ្ឋាន បន្ថែមលើមុខងារបច្ចុប្បន្ន ។

២- លោក ម៉ែន រិទ្ធី អនុប្រធាននាយកដ្ឋានផែនការ-គណនេយ្យ ជាជំនួយការ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីព្រះបរមរាជវាំង មានឋានៈស្មើប្រធាននាយកដ្ឋានបន្ថែមលើមុខងារបច្ចុប្បន្ន ។

៣- លោក យឹម វិណារុធ អនុប្រធាននាយកដ្ឋានរដ្ឋបាល ជាជំនួយការឯកឧត្តម ឧបនាយករដ្ឋមន្ត្រី និងជា រដ្ឋមន្ត្រីព្រះបរមរាជវាំង មានឋានៈស្មើប្រធាននាយកដ្ឋាន បន្ថែមលើមុខងារបច្ចុប្បន្ន ។

៤- លោក អួន សាយ អនុប្រធាននាយកដ្ឋាន គ្រប់គ្រងព្រះរាជតំណាក់ ជាជំនួយការឯកឧត្តម ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីព្រះបរមរាជវាំង មានឋានៈស្មើប្រធាននាយកដ្ឋាន បន្ថែមលើមុខងារបច្ចុប្បន្ន។

៥- លោក អ៊ិន រដ្ឋាសេរី អនុប្រធាននាយកដ្ឋានគ្រប់គ្រងព្រះរាជតំណាក់ ជាជំនួយការ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីព្រះបរមរាជវាំង មានឋានៈស្មើប្រធាននាយកដ្ឋាន បន្ថែមលើមុខងារ បច្ចុប្បន្ន។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋាន មុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ដូចមានចែងក្នុងមាត្រា១ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែកក្កដា ឆ្នាំ ២០០៤

ហ៊ុន សែន

ទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ . កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: [illegible]

អនុក្រឹត្យ
ស្តីពីការជូនមេដាយសហមេត្រី

៦៧

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា .

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី .

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា .

-តាមសំណើរបស់ រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី

សម្រេច

មាត្រា ១. ~

ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **ធិបឌិន្ទ** ជូន ឯកឧត្តម ***Victor V.SAMOILENKO*** ឯកអគ្គរដ្ឋទូតវិសាមញ្ញ និង ពេញសមត្ថភាព នៃ សហព័ន្ធរុស្ស៊ី ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលមានស្នាដៃល្អ និង គុណបំណាច់ខ្ពស់ ក្នុងការលើកស្ទួយចំណងមិត្តភាព និង កិច្ចសហប្រតិបត្តិការ រវាងប្រទេសទាំងពីរ *សហព័ន្ធរុស្ស៊ី* និង *ព្រះរាជាណាចក្រកម្ពុជា* ។

មាត្រា ២. ~

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រី ក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

B 49

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ..៧៩០...អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយសហមេត្រី
&&&&&
រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស / រកត / ១០៩៥ / ០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ម្រេ ច

មាត្រា ១.-

ត្រូវបានបំពាក់ **មេដាយសហមេត្រី** ថ្នាក់ **សេនា** ជូនលោកស្រីវេជ្ជបណ្ឌិត **Diny Van Bruggen , M.D.** ជនជាតិហូឡង់ ប្រធានអង្គការស្ពានកម្ពុជា ហូឡង់ ដែលមានស្នាដៃល្អ និង គុណបំណាច់ខ្ពស់ក្នុងការធ្វើសហប្រតិបត្តិការ ជួយកសាង និង អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសាធារណៈនានា ក្នុងខេត្តកំពង់ចាម ។

មាត្រា ២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ កក្កដា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និង មាត្រា២
-រាជកិច្ច
-ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៣៨១ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស /រកត /១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ម្រេ ច

មាត្រា ១. -

ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនសប្បុរសជនចំនួន ០៣ រូប ជាស្ថាបនិក និង ជាអ្នកគាំទ្រ អង្គការស្ពាន កម្ពុជា ហូឡង់ ដែលបានបរិច្ចាគធនធានចូលរួមជួយកសាងសមិទ្ធផលសាធារណៈផ្សេងៗ នៅខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោម ÷

១-លោក	**Piet Mars**	ជនជាតិហូឡង់	ថវិកាចំនួន ៥០.០០០ ដុល្លារ
២-លោកគ្រូគង្វាល	**Gerard de Kimpe**	ជនជាតិហូឡង់	ថវិកាចំនួន ៥០.០០០ ដុល្លារ
៣-លោក	**សែន សារ៉ា**	អភិបាលរងស្រុកស្រីសន្ធរ	ថវិកាចំនួន១០.០០០ដុល្លារ

មាត្រា ២. -

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/.

រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ កក្កដា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា១ និង មាត្រា២

-រាជកិច្ច /

-ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៣៩៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការផ្តល់មេដាយមុនីសារាភ័ណ្ឌ

&&&&&

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស /រកត /១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១. ~

ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** ថ្នាក់ **អស្សឫទ្ធិ** ជូនសប្បុរសជនចំនួន ០៣ រូប ជាស្ថាបនិក អង្គការស្ពានកម្ពុជា ហូឡង់ ដែលមានគុណបំណាច់ និង ស្នាដៃល្អ ក្នុងការជួយកសាង និង អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសាធារណៈនានា នៅខេត្តកំពង់ចាម ដូចមានរាយនាមខាងក្រោម ÷

១-អ្នកស្រី **អ៊ុយ សុមនា** ប្រធានគំរោងកម្មវិធីថែរក្សាជំងឺអេដស៍ និងកុមារកំព្រា

២-លោកសាស្ត្រាចារ្យ **ខួន ផាន**

៣-លោកគ្រូគង្វាល **ហ៊ាង ភុយ**

មាត្រា ២. ~

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តកំពង់ចាម ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ កក្កដា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-ដូចក្នុងមាត្រា១ និង មាត្រា២

-រាជកិច្ច

-ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:..៤១.សសរ.....

សេចក្តីសំរេច

ស្តីពី

ការបង្កើតគណៈកម្មការចំរុះ ចុះបង្ក្រាបបទល្មើសព្រៃឈើ នៅតំបន់កន្ទុយនាគ

ក្នុងឧទ្យានជាតិវីរៈជ័យ ខេត្តរតនៈគីរី

ះះះះះ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩១/៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពី ព្រៃឈើ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

សម្រេច

ប្រការ១.-

ត្រូវបានបង្កើតគណៈកម្មការចំរុះ ដើម្បីចុះធ្វើការបង្ក្រាបបទល្មើសព្រៃឈើ នៅតំបន់កន្ទុយនាគ ស្ថិតនៅក្នុងឧទ្យានជាតិវីរៈជ័យ ខេត្តរតនៈគីរី ដែលមានសមាសភាពដូចខាងក្រោម:

១- ឯកឧត្តម	ឆាន់	សាផាន	រដ្ឋលេខាធិការ ក្រសួងបរិស្ថាន	ប្រធាន
២- ឯកឧត្តម	ធឹក	គ្រឿនវុត្ថា	អនុរដ្ឋលេខាធិការ ក្រសួងបរិស្ថាន	អនុប្រធាន
៣- ឯកឧត្តម	អ៊ុក	សុខុន	អនុរដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	អនុប្រធាន

៤- ឯកឧត្តម ឧត្តមសេនីយឯក ខាំ នារា	នាយកទីចាត់ការកលយុទ្ធ និងជានាយរងសេនាធិការចំរុះ នៃអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ ក្រសួងការពារជាតិ	សមាជិក
៥- ឯកឧត្តម ឧត្តមសេនីយទោ ទន្សូ ពិសេន	មេបញ្ជាការរងកងរាជអាវុធហត្ថលើផ្ទៃប្រទេស	សមាជិក
៦- ឯកឧត្តម ឧត្តមសេនីយទោ ម៉ាន់ ណាយ	ប្រធាននាយកដ្ឋានកណ្ដាលនគរបាលយុត្តិធម៌នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ	សមាជិក
៧- ឯកឧត្តម ឈឹម ចាន់ណារាត	អគ្គាធិការ ក្រសួងបរិស្ថាន	សមាជិក
៨- លោក មួង ម៉ៃយ	អភិបាលរងទី២ខេត្ត រតនៈគិរី	សមាជិក
៩- លោក ចាយ សាមិត្ត	ប្រធាននាយកដ្ឋានការពារ និងអភិរក្សធម្មជាតិ ក្រសួងបរិស្ថាន	សមាជិក
១០- លោក មាស សុផល	ប្រធានតំរោងជីវចំរុះ និងតំបន់ការពារធម្មជាតិ នាយកដ្ឋានការពារ-អភិរក្សធម្មជាតិ ក្រសួងបរិស្ថាន	សមាជិកអចិន្ត្រៃយ៍

ប្រការ២.-

គណៈកម្មការចំរុះនេះមានតួនាទី និងភារកិច្ច ដូចតទៅ :

១- ចុះទប់ស្កាត់ និងបង្ក្រាបសកម្មភាពអនាធិបតេយ្យកាប់ព្រៃឈើ នាំចេញខុសច្បាប់ និងប្រមូលវត្ថុតាងជាក់ស្ដែងទុកនៅនឹងកន្លែងឱ្យបានសំរេចទាន់ពេលវេលា

២- ស្រាវជ្រាវរកអ្នកដែលពាក់ពន្ធ័ នឹងសកម្មភាពកាប់ និងនាំចេញឈើល្មើសច្បាប់នេះ

៣- សហការជាមួយភាគីឡាវ និងវៀតណាម ដើម្បីចុះកិច្ចសហប្រតិបត្តិការរួមក្នុងការចុះទប់ស្កាត់ បង្ក្រាបបទល្មើស និងស្រាវជ្រាវរកអ្នកពាក់ពន្ធ័នឹងបទល្មើសនេះ

៤- បូកសរុបរបាយការណ៍ជូនរាជរដ្ឋាភិបាល អំពីលទ្ធផលនៃការចុះបង្ក្រាបបទល្មើសព្រៃឈើនៅតំបន់កន្ទុយនាគ ខេត្តរតនៈគិរី

៥- រៀបចំកសាងសំណុំរឿងបញ្ជូនទៅតុលាការ

ប្រការ៣.-

សមាជិកគណៈកម្មការចំរុះនេះ ត្រូវទទួលខុសត្រូវក្នុងការអនុវត្តន៍ភារកិច្ចខាងលើឱ្យមានប្រសិទ្ធភាព និងចូលរួមប្រជុំការងារតាមការកោះអញ្ជើញរបស់ប្រធានគណៈកម្មការ ។

ប្រការ៤.-

គណៈកម្មការចំរុះនេះ មានសិទ្ធិបង្កើតអនុគណៈកម្មការមួយតាមការចាំបាច់ ដែលមានសមាភាពមកពីក្រសួង ស្ថាប័នពាក់ពន្ធ័ចូលរួម និងស្នើសុំកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទចូលរួមជាកម្លាំងក្នុងពេលចុះបេសកកម្ម ។

ប្រការ៥.-

គណៈកម្មការចំរុះនេះ មានលេខាធិការដ្ឋានអចិន្ត្រៃយ៍នៅក្រសួងបរិស្ថាន និងមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងបរិស្ថាន ដើម្បីអនុវត្តភារកិច្ច និងសំរួលការងាររបស់ខ្លួន ។

ប្រការ៦.-

អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងកំលាំងប្រដាប់អាវុធគ្រប់ប្រភេទ ដែលឈរជើងក្នុងតំបន់នោះ ត្រូវសហការ ចូលរួមធ្វើអន្តរាគមន៍ និងបង្កលក្ខណៈងាយស្រួល ដល់គណៈកម្មការចំរុះ ក្នុងការចុះអនុវត្តភារកិច្ចរបស់ខ្លួនឱ្យបានជោគជ័យ ។

ប្រការ៧.-

រាល់ការចំណាយលើបេសកកម្មចុះទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើនៅតំបន់កន្ទុយនាគនេះ ជាបន្ទុករបស់ក្រសួងបរិស្ថាន ។

ប្រការ៨.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងបរិស្ថាន សហរដ្ឋមន្ត្រីក្រសួងការពារជាតិ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ អគ្គមេបញ្ជាការកងយោធពលខេមរភូមិន្ទ អភិបាលខេត្តរតនៈគីរី និងសមាសភាពដូចមានចែង ក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចក្នុងប្រការ៦ និងប្រការ៨
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
KINGDOM OF CAMBODIA
Nation - Religion - King

ក្រសួងពាណិជ្ជកម្ម
Ministry of Commerce
No ១៣៣ MOC / M 2004

ប្រកាស
ស្តីពីការផ្ទេរអចលនវត្ថុ

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៦៩ ចុះថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការចាត់តាំងនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅ នៃក្រសួងពាណិជ្ជកម្ម
- បានឃើញលិខិតលេខ ១៦២០ សហវ.ទរ ចុះថ្ងៃទី ៩ ខែ មេសា ឆ្នាំ២០០៤ របស់ក្រសួងសេដ្ឋកិច្ច-ហិរញ្ញវត្ថុ
- បានឃើញកំណត់ហេតុស្តីពីការផ្ទេរទីតាំងដី និង ឃ្លាំងកន្ទុយវៃ ចុះថ្ងៃទី ០២ ខែ មិថុនា ឆ្នាំ ២០០៤

សំរេច

ប្រការ ១ : ផ្ទេរការគ្រប់គ្រងទីតាំងដី និង ឃ្លាំងកន្ទុយវៃរបស់មន្ទីរពាណិជ្ជកម្មខេត្តស្វាយរៀង ជូនសាលាខេត្តស្វាយរៀង សំរាប់សាងសង់សកលវិទ្យាល័យ ។

ប្រការ ២ : នាយកដ្ឋានគណនេយ្យហិរញ្ញវត្ថុ មន្ទីរពាណិជ្ជកម្មខេត្តស្វាយរៀង រៀបចំជំរះបញ្ជីអចលនវត្ថុទៅតាមបែបបទដែលរដ្ឋបានកំណត់ ។

ប្រការ ៣ : អគ្គនាយកដ្ឋានរដ្ឋបាល-ហិរញ្ញវត្ថុ ខុទ្ទកាល័យឯកឧត្តមរដ្ឋមន្ត្រី នាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ មន្ទីរពាណិជ្ជកម្មខេត្តស្វាយរៀង មានភារកិច្ចរៀងៗខ្លួន អនុវត្តប្រកាសនេះអោយមាន ប្រសិទ្ធិភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ , ថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០៤

រដ្ឋមន្ត្រី

ចម ប្រសិទ្ធ

ចំលងជូន

- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ដូចក្នុងប្រការ ៣ " ដើម្បីអនុវត្ត "
- រាជកិច្ច ✓
- ឯកសារ កាលប្បវត្តិ

DAF/ Prakas on Transfer Asset to Svay Rieng /Sey/Cheat/ST/ 05-07-04

